ព្រះរាជាណាចក្រកម្ពុជា
ជាតិ សាសនា ព្រះមហាក្សត្រ

ក្រសួងសេដ្ឋកិច្ច និង ហិរញ្ញវត្ថុ
អគ្គនាយកដ្ឋានពន្ធដារ
លេខ ៣២៥២១ អពដ

សារលិខិតជូនពរ និងអបអរសាទរ

ឯកឧត្តមកិត្តិសេដ្ឋាបណ្ឌិត គាត ឈន់ ប្រធានកិត្តិយសឧត្តមក្រុមប្រឹក្សាសេដ្ឋកិច្ចជាតិ

តាងនាមថ្នាក់ដឹកនាំ និងមន្ត្រីរាជការនៃអគ្គនាយកដ្ឋានពន្ធដារ ខ្ញុំបាទសូមគោរពអនុញ្ញាតជូនពរ និងសម្តែងនូវអំណរសាទរដោយស្មោះត្រង់ស្មោះជាទីបំផុត ប្រកបដោយមនោសញ្ចេតនារំភើបសប្បាយរីករាយក្រៃលែង ក្នុងឱកាសដ៏ប្រសើរថ្លៃថ្លាប្រកបដោយមោទនភាពសម្រាប់ប្រជាជាតិកម្ពុជាទាំងមូល ដែល **ឯកឧត្តមកិត្តិសេដ្ឋាបណ្ឌិត** ត្រូវបានផ្តល់ជូននូវគ្រឿងឥស្សរិយយស **“The Grand Cordan of the Order of the Rising Sun”** ដែលជាគ្រឿងឥស្សរិយយសថ្នាក់ខ្ពស់បំផុតលេខ១ របស់រដ្ឋាភិបាលជប៉ុនសម្រាប់ជនបរទេសដែលបានរួមចំណែកក្នុងការពង្រឹងនិងពង្រីកកិច្ចសហប្រតិបត្តិការ និងទំនាក់ទំនងមិត្តភាពរវាងប្រទេសជប៉ុន និងព្រះរាជាណាចក្រកម្ពុជា។

ក្នុងពេលកាន់តំណែងជារដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុនៃព្រះរាជាណាចក្រកម្ពុជា **ឯកឧត្តមកិត្តិសេដ្ឋាបណ្ឌិត** បានខិតខំយ៉ាងសកម្ម រួមចំណែកយ៉ាងធំធេងក្នុងការកៀរគរជំនួយអភិវឌ្ឍន៍ផ្លូវការ (ODA) ពីរដ្ឋាភិបាលជប៉ុន ដើម្បីស្តារនិងអភិវឌ្ឍកម្ពុជា ពីស្ថានភាពខ្ទេចខ្ទាំជាគំនរផេះផង់ដោយសារសង្គ្រាម ពីចំណុចសូន្យ ឱ្យក្លាយមកជាប្រទេសដែលមានកំណើនសេដ្ឋកិច្ច និងត្រូវបានទទួលស្គាល់ថាជាកូនខ្លាសេដ្ឋកិច្ចនៅអាស៊ី។ **ឯកឧត្តមកិត្តិសេដ្ឋាបណ្ឌិត** គឺជាតួអង្គដ៏សំខាន់មួយរូបក្នុងការពង្រឹងនិងពង្រីកចំណងមិត្តភាព ភាតរភាព រវាងប្រជាជាតិទាំងពីរ កាន់តែជិតស្និទ្ធស្និតល្អូតទ្រៅឡើងជាប្រវត្តិសាស្ត្រថែមទៀត។

កិត្តិយសដ៏ឧត្តុង្គឧត្តមដែល **ឯកឧត្តមកិត្តិសេដ្ឋាបណ្ឌិត** ទទួលបាន គឺជាការលើកស្ទួយនូវកិត្យានុភាពប្រទេសជាតិទាំងលើឆាកជាតិ និងអន្តរជាតិ និងជាការបង្ហាញនូវភាពជោគជ័យដ៏ត្រចះត្រចង់ក្នុងការអនុវត្តគោលនយោបាយការបរទេសរបស់រាជរដ្ឋាភិបាលកម្ពុជា ក្រោមអគ្គមហាមគ្គុទ្ទេសក៍ដ៏ឆ្នើមប្រកបដោយគតិបណ្ឌិត ភាពឈ្លាសវៃ និងបញ្ញាញាណដ៏ភ្លឺស្វាងរបស់**សម្តេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន** ដោយធ្វើឱ្យកម្ពុជាសម្រេចបាននូវការផ្លាស់ប្តូរមុខមាត់ថ្មី ដ៏គួរជាទីមោទនៈបំផុត។

ក្នុងឱកាសប្រកបដោយមហាកិត្តិយសជាតិ ខ្ញុំបាទសូមបួងសួងដល់វត្ថុស័ក្តិសិទ្ធិក្នុងលោក ទេវតា ថែរក្សាទឹកដីព្រះរាជាណាចក្រកម្ពុជា គុណបុណ្យព្រះរតនត្រ័យគុណកែវទាំងបី ទេវតាថែរក្សាឆ្នាំថ្មី សូមព្រះអង្គតាមជួយអភិបាលរក្សា ប្រោះព្រំសព្ទសាធុការពរជ័យ បវរសួស្តី សិរីមង្គល វិបុលសុខ មហាប្រសើរ ជូន **ឯកឧត្តមកិត្តិសេដ្ឋាបណ្ឌិត** និង **លោកជំទាវ** ព្រមទាំងបុត្រា បុត្រី ចៅប្រុស ចៅស្រី សូមសមប្រកបដោយសុខភាពល្អបរិបូណ៌ ពលានុភាពមាំមួន ជន្មាយុយឺនយូរ និងសូមសមប្រកបដោយពុទ្ធពរទាំងបួនប្រការគឺ អាយុ វណ្ណៈ សុខៈ និងពលៈ កុំបីឃ្លៀងឃ្លាតឡើយ។

សូម **ឯកឧត្តមកិត្តិសេដ្ឋាបណ្ឌិត** មេត្តាទទួលនូវអភិវន្ទនកិច្ចដ៏ខ្ពង់ខ្ពស់ និងភក្តីភាពដ៏ស្មោះស្ម័គ្របំផុត ពីខ្ញុំបាទ។

រាជធានីភ្នំពេញ, ថ្ងៃពុធ ០៣ កើត ខែបុស្ស ឆ្នាំរកា នព្វស័ក ព.ស. ២៥៦១
ត្រូវនឹងថ្ងៃទី២០ ខែធ្នូ គ.ស. ២០១៧
ប្រតិភូរាជរដ្ឋាភិបាល
ទទួលបន្ទុកជាអគ្គនាយកនៃអគ្គនាយកដ្ឋានពន្ធដារ

អគ្គនាយកដ្ឋាន ពន្ធដារ

គង់ វិបុល

អាគារកែងមហាវិថី សហព័ន្ធរុស្ស៊ី(១១០)និង ម៉ៅសេទុង(២៤៥) សង្កាត់ទឹកល្អក់១ ខណ្ឌទួលគោក រាជធានីភ្នំពេញ ព្រះរាជាណាចក្រកម្ពុជា
ទូរស័ព្ទ (+855) 23 886 708 ទូរសារ: (+855)23 886 700, Email: gdt@tax.gov.kh, Website: www.tax.gov.kh